# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជានៅព្រះសហគមន៍សន្តីម៉ារីញញឹម
# ចំការទៀង ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២០
## អ្នកណាមានវិន័យរបស់ខ្ញុំនិងប្រព្រឹត្តតាម គឺអ្នកនោះហើយដែលស្រឡាញ់ខ្ញុំ

**អត្ថបទទី១៖ កិច្ចការ ៨,៥-៨.១៤-១៧**

ពេលនោះ លោកសិលា និងលោកយ៉ូហានបានដាក់ដៃ*លើគេ ហើយគេក៏បានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ។ កក ៨,១៧

**អត្ថបទទី២៖ ពេត្រុសទី១ ៣,១៥-១៨**

ស៊ូរងទុក្ខដោយប្រព្រឹត្តអំពើល្អ ជាជាងប្រព្រឹត្តអំពើអាក្រក់ ប្រសិនបើព្រះជាម្ចាស់សព្វព្រះហឫទ័យយ៉ាងនេះ។ ១ពត្រ ៣,១៧

**ដំណឹងល្អ៖ យ៉ូហាន ១៤,១៥-២១**

អ្នកណាមានវិន័យរបស់ខ្ញុំ និងប្រតិបត្តិតាម គឺអ្នកនោះហើយដែលស្រឡាញ់ខ្ញុំ។ យហ ១៤,២១

បងប្អូនជាទីស្រឡាញ់!

នៅពេលយើងបានស្តាប់អត្ថបទទីមួយ នឹកឃើញបងប្អូនថ្មីៗដែលទន្ទឹងរង់ចាំទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីទៅជាគ្រីស្តបរិស័ទដ៏ពេញលក្ខណៈ ដោយសារគេបានទទួលតែពិធីជ្រមុជទឹកក្នុងនាមព្រះអម្ចាស់យេស៊ូប៉ុណ្ណោះ។ ប៉ុន្តែ មានគ្រីស្តទូត លោកសិលា និងលោកយ៉ូហានដាក់ដៃលើគេហើយគេទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ហើយនៅពេលនោះគេពោរពេញដោយអំណរសប្បាយ។ នៅពេលយើងស្តាប់នេះហើយ យើងត្រូវតែអធិដ្ឋានថែមទៀតសម្រាប់បងប្អូនរបស់យើងដែលបានធ្វើជំហានទីពីរ និងដែលមិនទាន់បានធ្វើពិធីជ្រមុជទឹកដោយសារកូវីដ១៩ ដែលណែនាំឲ្យយើងផ្អាកគ្រប់សកម្មភាពធំៗនៅក្នុងសាសនានានា និងនៅក្នុងសាសនារបស់យើងជាសាសនាកាតូលិកដែរ។

នៅពេលនេះខ្ញុំសូមអធិដ្ឋាន សូមផ្ញើក្តីនឹករលឹកជាពិសេសដល់បងប្អូនជំហានទីពីរជាង ៧០នាក់ នៅក្នុងភូមិភាគភ្នំពេញដែលកំពុងទន្ទឹងរង់ចាំទទួលទាំងពិធីជ្រមុជទឹក ទាំងព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះយេស៊ូជិតទៅហើយ ពីថ្ងៃបុណ្យចម្លងរហូតដល់ថ្ងៃព្រហស្បតិ៍ខាងមុខ ៤០ថ្ងៃដែលព្រះយេស៊ូបានបង្ហាញខ្លួន ៤០ថ្ងៃដែលព្រះយេស៊ូបានខិតខំប្រទានសេចក្តីសុខដល់ក្រុមគ្រីស្តទូត ៤០ថ្ងៃដែលព្រះយេស៊ូបានធ្វើដំណើរដើម្បីឲ្យក្រុមគ្រីស្តទូតយល់ថាពិតមែន ព្រះអង្គមានព្រះជន្មរស់ឡើងវិញ ពិតមែនព្រះយេស៊ូបានឈរឡើងពីសេចក្តីស្លាប់ ដើម្បីណែនាំឲ្យយើងទាំងអស់អាចទទួលជីវិតអស់កល្បជានិច្ច។ ថ្ងៃព្រហស្បតិ៍ខាងមុខ គឺ៤០ថ្ងៃដែលព្រះយេស៊ូឡើងស្ថានបរមសុខ

លែងនៅជាមួយយើងផ្ទាល់ លែងនៅជាមួយក្រុមគ្រីស្តទូតផ្ទាល់។ ប៉ុន្តែ នៅក្នុងអត្ថបទគម្ពីរថ្ងៃនេះយើងបានឃើញ "**កុំព្រួយបារម្ភ**" កុំគិតថាឥលូវនេះខ្ញុំទុកឲ្យក្រុមគ្រីស្តទូត ទុកឲ្យបងប្អូនទាំងអស់កំព្រារ។ ផ្ទុយទៅវិញ ខ្ញុំទៅជួបជាមួយព្រះបិតាផ្ទាល់ និងខ្ញុំបានផ្ញើព្រះមួយពិសេសគឺ "**ព្រះវិញ្ញាណដ៏វិសុទ្ធ**" ដើម្បីធ្វើដំណើរជាមួយបងប្អូនទាំងអស់។ ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាសេចក្ដីពិត ព្រះវិញ្ញាណដ៏វិសុទ្ធដែលណែនាំឲ្យយើងស្គាល់ព្រះបិតាថែមទៀត ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជំរុញយើងឲ្យយើងចេះស្រឡាញ់គ្នាទៅវិញទៅមក ដើម្បីធ្វើតាមធម្មវិន័យរបស់ព្រះយេស៊ូផ្ទាល់។

បងប្អូនជាទីស្រឡាញ់! យើងជាប្រជារាស្ត្រដែលបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ យើងជាប្រជារាស្ត្រដែលរស់នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីធ្វើដំណើរនៅក្នុងលោកនេះ។ ប៉ុន្តែលោកីយ៍មិនទទួលស្គាល់ព្រះជាម្ចាស់ លោកីយ៍មិនទទួលវត្តមានរបស់ព្រះអង្គ ដោយសារគេអត់ស្គាល់។ ប្រសិនបើគេស្គាល់ ប្រហែលនរណាក៏ដើរតាមព្រះជាម្ចាស់ នរណាក៏ដើរតាមព្រះយេស៊ូ ប៉ុន្តែគេអត់ស្គាល់ដូចព្រះយេស៊ូបានបំភ្លឺនៅក្នុងគម្ពីរថ្ងៃនេះ។ ក៏ប៉ុន្តែយើង ដែលបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធយើងស្គាល់ ហើយដោយសារយើងស្គាល់ព្រះយេស៊ូ យើងស្គាល់ព្រះបិតា អ្នកណាដែលបានឃើញព្រះយេស៊ូ អ្នកនោះបានឃើញព្រះបិតា។

ខ្ញុំបានចាប់អារម្មណ៍ នៅពេលគេបិទពិភពលោក ជិតពាក់កណ្ដាលនៃប្រជាជននៅក្នុងពិភពលោកជិតពីរខែកន្លង អត់មានសិទ្ធិចេញពីផ្ទះ អត់មានសិទ្ធិធ្វើដំណើរ អត់មានសិទ្ធិជួបជុំគ្នា។ នៅពេលប្រទេសនីមួយៗ បានបិទសិទ្ធិសេរីភាពមិនឲ្យចេញពីផ្ទះដើម្បីធ្វើដំណើរ គេបានទុកតែសិទ្ធិខ្លះៗដែលគេថា ជាអាទិភាពបំផុតសម្រាប់ជីវិត។ ខ្ញុំលើកឧទាហរណ៍ ឪពុកម្ដាយខ្ញុំនៅប្រទេសបារាំង ជិតពីរខែអត់មានសិទ្ធិចេញពីផ្ទះ គាត់មានសិទ្ធិចេញពីផ្ទះដើម្បីទី១ទៅផ្សារទិញម្ហូបអាហារ ដូច្នេះម៉ែមួយអាទិត្យម្ដងទៅផ្សារទិញម្ហូបអាហារ។ ទី២ ប្រសិនបើឈឺអាចទៅមន្ទីរពេទ្យបាន ជាពិសេសនៅក្នុងកូវីដ១៩មានអ្នកជំងឺច្រើន ដូច្នេះគេបានចូលមន្ទីរពេទ្យដើម្បីព្យាបាលសុខភាព។ ទី៣ គឺអ្នកដែលត្រូវការធ្វើការជាចាំបាច់ដើម្បីឲ្យសង្គមទៅមុខ ដូចជាអ្នកធ្វើការនៅក្នុងផ្សារ អ្នកធ្វើការនៅក្នុងមន្ទីរពេទ្យ អ្នកធ្វើការខាងអនាម័យទីក្រុងនីមួយៗ អ្នកធ្វើការខាងអគ្គីសនី អ្នកទទួលខុសត្រូវទឹក ទទួលខុសត្រូវអនាម័យ។ល។

ប្រសិនបើយើងពិចារណាបន្តិច មនុស្សយើងពិតមែនត្រូវការញ៉ាំបាយ មនុស្សយើងពិតមែនត្រូវការព្យាបាលសុខភាព មនុស្សយើងពិតមែនត្រូវការធ្វើការដើម្បីមានលុយ ដើម្បីឲ្យសង្គមទៅមុខនិងមានប្រាក់ខែចិញ្ចឹមគ្រួសារ។ ខ្ញុំចង់សួរដល់ពិភពលោកទាំងមូល **តើនៅមានខ្វះអ្វី? មូលហេតុអ្វីផ្លូវវិញ្ញាណមិនមែនទៅជាសិទ្ធិអាទិភាពជាចាំបាច់? មូលហេតុអ្វីជីវិតរបស់មនុស្សយើងដែលមានរូបកាយមែន ដែលត្រូវតែមានសុខភាពល្អមែន ដែលត្រូវតែមានលុយដើម្បីធ្វើការដើម្បី**

**ចិញ្ចឹមជីវិត ដើម្បីថែរក្សាគ្រួសារមែន មិនទទួលស្គាល់ថាផ្លូវវិញ្ញាណជាអាទិភាពនៃជីវិតរបស់យើងដែរ?** ផ្លូវវិញ្ញាណសំខាន់ណាស់ ខ្ញុំបានឃើញនៅប្រទេសជាច្រើន អ្នកដែលបានស្លាប់នៅមន្ទីរពេទ្យ នៅពេលនោះគេអត់មានសិទ្ធិជួបជាមួយបូជាចារ្យ គេអត់មានសិទ្ធិជួបជាមួយលោកឪពុកឬបងស្រី ដើម្បីធ្វើដំណើរចុងក្រោយបំផុតនៅលើផែនដីនេះជាមួយពួកគាត់។ អត់មានសិទ្ធិទទួលព្រះកាយចុងក្រោយ អត់មានសិទ្ធិទទួលអគ្គសញ្ញាលើកលែងទោសចុងក្រោយ។ ពេលយើងស្តាប់អត្ថបទនៅថ្ងៃនេះយើងយល់ហើយ មនុស្សលោកីយ៍មិនទទួលស្គាល់ព្រះបិតា។ ប៉ុន្តែ យើងដែលជាគ្រីស្តបរិស័ទឲ្យយើងទទួលសិទ្ធិរបស់យើង គឺទទួលជីវិតខាងផ្លូវវិញ្ញាណ សិទ្ធិរបស់យើងគឺទទួលព្រះកាយព្រះគ្រីស្ត។ សិទ្ធិរបស់យើងគឺប្រកាសដំណឹងល្អ ដូចដែលយើងបានខិតខំធ្វើក្នុងក្រុមគ្រីស្តទូត ដែលយើងបានបង្កើតទូទាំងភូមិភាគភ្នំពេញទាំងមូល។ សិទ្ធិរបស់យើងគឺចែករំលែកសេចក្តីស្រឡាញ់យ៉ាងជាក់ស្តែងដល់បងប្អូនឯទៀតៗ ដូចយើងបានធ្វើនៅក្នុងប៉ុន្មានកន្លែងកន្លងមក ជាមួយអ្នកក្រីក្រ ជាមួយអ្នកជំងឺ ជាមួយអ្នកតូចតាច។ នេះជាសិទ្ធិដែលយើងមាន សិទ្ធិនិងតួនាទីរបស់យើងចិញ្ចឹមជីវិតខាងផ្លូវវិញ្ញាណ។

ដូច្នេះ ថ្ងៃនេះយើងសូមអរព្រះគុណព្រះយេស៊ូផ្ទាល់ ដែលបានផ្ញើព្រះវិញ្ញាណដ៏វិសុទ្ធដែលបានផ្ញើព្រះអង្គដែលជួយការពារយើង។ ជួយការពារសិទ្ធិរបស់យើង ជាមនុស្សម្នាក់ដែលព្រះជាម្ចាស់បានបង្កើត ដង្ហើមនៃជីវិតរបស់មនុស្សយើង ដង្ហើមនៃសួតរបស់យើងដែលយើងមានជាប្រចាំថ្ងៃមកពីព្រះវិញ្ញាណដ៏វិសុទ្ធ។ ជាដង្ហើមមួយដ៏សំខាន់ណាស់ យើងទទួលជីវិតពីឪពុកម្តាយមែន ប៉ុន្តែយើងទទួលជីវិតពីព្រះជាម្ចាស់ផ្ទាល់។ ប្រសិនបើ យើងនៅឆ្ងាយពីព្រះជាម្ចាស់បន្តិចម្តងៗដង្ហើមរបស់យើងតិចទៅៗ ហើយនៅពេលយើងអស់ដង្ហើម យើងដាច់ខ្យល់មានន័យថាយើងស្លាប់។

ថ្ងៃនេះ យើងរួមគ្នាអធិដ្ឋាន ដើម្បីឲ្យព្រះសហគមន៍របស់យើងបន្តបំពេញសិទ្ធិដែលយើងបានទទួល។ ប៉ុន្តែប្រយ័ត្ន យើងមានសិទ្ធិប៉ុន្តែមានតួនាទី ថ្ងៃនេះព្រះយេស៊ូនិយាយច្បាស់អំពីតួនាទីរបស់យើងគឺ "**ប្រសិនបើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ អ្នករាល់គ្នាពិតជាកាន់តាមវិន័យរបស់ខ្ញុំ**"។ តួនាទីរបស់យើងគឺ ស្រឡាញ់ព្រះជាម្ចាស់ ស្រឡាញ់ព្រះយេស៊ូ ប្រសិនបើយើងស្រឡាញ់ព្រះយេស៊ូពិតមែន យើងកាន់វិន័យរបស់ព្រះអង្គ។ វិន័យរបស់ព្រះអង្គ គឺស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះអង្គបានស្រឡាញ់យើងដែរ។ សូមគិត! "**ស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូបានស្រឡាញ់យើង**" នេះជាតួនាទីរបស់យើងជាគ្រីស្តបរិស័ទ អនុវត្តតាមធម្មវិន័យរបស់ព្រះអង្គនៅក្នុងគ្រប់កាលៈទេសៈនៃជីវិតរបស់យើងដើម្បីធ្វើដំណើរទៅមុខ។ "**អ្នកណាមានវិន័យរបស់ខ្ញុំនិងប្រព្រឹត្តតាម គឺអ្នកនោះហើយដែលស្រឡាញ់ខ្ញុំ**" ដូច្នេះកុំគិតវែងឆ្ងាយ ស្រឡាញ់ព្រះយេស៊ូលុះ

គ្រាតែយើងគោរព យើងអនុវត្ត យើងរស់នៅតាមធម្មវិន័យរបស់ព្រះយេស៊ូ ស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូបានស្រឡាញ់យើងដែរ។ នៅក្នុងអត្ថបទទីមួយគេសប្បាយចិត្តណាស់ ដោយសារមានខ្មោចជាច្រើនចេញពីមនុស្សទាំងស្រែកខ្លាំងៗ មានមនុស្សខ្វិន មនុស្សពិការដៃជើងជាច្រើនបានជាសះស្បើយ។ សម័យដើមក្រុមគ្រីស្តទូតណែនាំឲ្យខ្មោចចេញ ណែនាំឲ្យមនុស្សខ្វិនដើរបាន មនុស្សខ្វាក់មើលឃើញ ដូចព្រះយេស៊ូបានធ្វើពីដើម។ គេអាចធ្វើបានដោយសារគេបានភ្ជាប់ជាមួយធម្មវិន័យរបស់ព្រះអង្គយ៉ាងខ្លាំង ដោយសារគេបានផ្ញើជីវិតទាំងស្រុងទៅលើព្រះអង្គដែលជាទីពឹងរបស់គេទាំងស្រុង ដែលណែនាំឲ្យគេទទួលអំណាចមកពីព្រះជាម្ចាស់ ឫទ្ធិបារមីដែលមកពីព្រះជាម្ចាស់ ដើម្បីណែនាំឲ្យមនុស្សអាចរកឃើញជីវិតថ្មី ដោយទទួលការលើកលែងទោស និងដោយរំដោះពីអំពើបាបដើម្បីធ្វើដំណើរតទៅទៀត។

យើងអរព្រះគុណព្រះជាម្ចាស់ ដោយសារពីម្សិលមិញនៅប្រទេសកម្ពុជា អ្នកជំងឺកូវីដ១៩បានជាសះស្បើយទាំងអស់។ យើងបានជោគជ័យ១០០% យើងត្រូវតែអបអរសាទរដល់រដ្ឋាភិបាល ដល់ក្រសួងសុខាភិបាលដែលបានដឹកនាំប្រជារាស្ត្រផ្ទាល់ខ្លួន ដើម្បីឲ្យយើងឈ្នះកូវីដ១៩ទាំងស្រុង។ យើងបន្តបិទសាលារៀនរហូតដល់ថ្ងៃណាយើងមិនទាន់ដឹងច្បាស់ ប៉ុន្តែដោយដឹងថាយើងភ័យខ្លាចអំពីរលកទីពីរ ហើយយើងមើលអ្វីដែលកើតឡើងនៅក្នុងតំបន់យើង នៅអាស៊ីអាគ្នេយ៍និងនៅក្នុងពិភពលោកដែរ។ ដូច្នេះ យើងបន្តគោរពការបិទសាលា អំពីសាសនាពីរខែកន្លងមកយើងបានយកចិត្តទុកដាក់អស់ពីសមត្ថភាព នៅតាមកន្លែងនីមួយៗដែលយើងអាចប្រមូលគ្រីស្តបរិស័ទខ្លះៗដើម្បីអធិដ្ឋាន ដើម្បីទទួលការអប់រំជំនឿ ដើម្បីធ្វើសកម្មភាពមេត្តាករុណា ដើម្បីទទួលព្រះកាយព្រះគ្រីស្តនៅក្នុងពិធីបុណ្យអភិបូជា។ ជាពេលវេលា ដើម្បីឲ្យព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺយើង ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងមានគំនិតថ្មីៗគ្រប់ពេលវេលា។ ព្រះវិញ្ញាណដ៏វិសុទ្ធ ណែនាំឲ្យយើងរស់នៅតាមធម្មវិន័យរបស់ព្រះយេស៊ូ។ គ្រីស្តបរិស័ទប្រសិនបើរស់នៅក្រោមព្រះវិញ្ញាណដ៏វិសុទ្ធ មិនស្ងិត មិនអស់យោបល់ មិនអសកម្ម។ ផ្ទុយទៅវិញ អាចមានគំនិតថ្មីៗស្របតាមព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីទៅមុខតទៅទៀត។

យើងបន្តអធិដ្ឋាន យើងបន្តស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូបានស្រឡាញ់យើង ហើយនៅពេលហ្នឹងយើងដឹងថា ពិតមែនព្រះយេស៊ូគង់នៅជាមួយយើងអស់កល្បជានិច្ច ពិតមែនយើងភ្ជាប់ជាមួយព្រះបិតា ដែលស្រឡាញ់យើងយ៉ាងខ្លាំងណាស់។ អាម៉ែន៕